**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ.ធ៥.១៧-០១៨-០០៧ ជ.ក.៧.ឱ

ថ្ងៃ សុក្រ ២ រោច ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ២០១៨

**សេចក្តីប្រកាសព័ត៌មាន**
**ស្តីពី ផលវិបាកនៃការប្រើប្រាស់កម្ចីខុសច្បាប់**

ធនាគារជាតិនៃកម្ពុជាបានកត់សម្គាល់ឃើញថា ថ្មីៗនេះក្រុមហ៊ុនឯកជនមួយចំនួនបានផ្សព្វផ្សាយជាសាធារណៈយ៉ាងសកម្មតាមរយៈ បណ្តាញសង្គម ការចែកនាមប័ណ្ណ និងផ្ញើសារតាមទូរស័ព្ទ ជាដើម។ អាស្រ័យហេតុនេះ ធនាគារជាតិនៃកម្ពុជា សូមជម្រាបជូនសាធារណជនពីផលវិបាកធំៗ ដែលបណ្តាលមកពីការប្រើប្រាស់កម្ចីខុសច្បាប់ ដូចខាងក្រោម ៖

- អតិថិជនអាចប្រឈមមុខនឹងបំណុលវ័ណ្ឌក ដោយសារអត្រាការប្រាក់និងកម្រៃសេវាផ្សេងៗខ្ពស់យ៉ាងខ្លាំងជាងគ្រឹះស្ថានដែលស្របច្បាប់ និងការគណនាការប្រាក់ពុំត្រឹមត្រូវតាមច្បាប់ និងបទប្បញ្ញត្តិ
- អតិថិជនអាចប្រឈមមុខនឹងការគំរាមកំហែង គៀបសង្កត់ គ្រោះថ្នាក់ ឬ រូបភាពផ្សេងៗ ដើម្បីបង្ខំឲ្យសងប្រាក់ដើម ការប្រាក់ និងប្រាក់ពិន័យដែលមិនសមហេតុផលទៅក្រុមហ៊ុនវិញ
- ទ្រព្យធានារបស់អតិថិជនអាចត្រូវបានក្រុមហ៊ុន ឬ អ្នកផ្តល់កម្ចីខុសច្បាប់ រឹបអូសដោយពុំឆ្លងកាត់ការសម្រេចពីតុលាការ ជាដើម។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជនជ្រាបជាព័ត៌មាន និងស្នើសុំសាធារណជនបង្កើនការប្រុងប្រយ័ត្ន និងជៀសវាងការប្រើប្រាស់សេវាកម្មកម្ចីពីក្រុមហ៊ុន ឬ អ្នកផ្តល់កម្ចីដែលគ្មានច្បាប់អនុញ្ញាតទាំងនោះ។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាបានកំពុងនឹងស្នើសុំការសហការពីអាជ្ញាធរពាក់ព័ន្ធដើម្បីចាត់វិធានការតាមផ្លូវច្បាប់ទៅលើក្រុមហ៊ុន ឬ អ្នកផ្តល់កម្ចីខុសច្បាប់គ្រប់រូបភាពទាំងអស់។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង ៖
អគ្គនាយកដ្ឋានត្រួតពិនិត្យ ធនាគារជាតិនៃកម្ពុជា
ទូរស័ព្ទ ៖ (៨៥៥) ៨៥ ៦០០ ០០២